# ស្ថិតិអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអ៊ីនធឺណិត

អំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងអំពើជួញដូរមនុស្សតាមអ៊ីនធឺណិតមានទំនាក់ទំនងគ្នាយ៉ាងស៊ីជម្រៅ ដែលជារឿយៗត្រួតលើគ្នាតាមរបៀបដែលជំរុញគ្នាទៅវិញទៅមក។



អ្នកប្រើប្រាស់អ៊ិនធឺណិត ១ ក្នុងចំណោម ៣នាក់ នៅទូទាំងពិភពលោក មានអាយុក្រោម ១៨ ឆ្នាំ។ [១]



៧៨ ភាគរយនៃរបាយការណ៍ទាក់ទងនឹងការទាក់ទាញតាមអ៊ីនធឺណិតសម្រាប់មាតិកាផ្លូវភេទត្រូវបានតម្រង់ទៅរកជាពិសេសក្មេងស្រី។ [៣]



៦៧ ភាគរយ នៃអ្នករស់រានមានជីវិតពីអំពើរំលោភបំពានផ្លូវភេទលើកុមារតាមរយៈ(CSAM) បាននិយាយថា ការចែកចាយរូបភាពរបស់ពួកគេវាបានធ្វើឲ្យប៉ះពាល់ខ្លាំងជាងការរំលោភបំពានដោយផ្ទាល់ទៀត ពីព្រោះថាការចែកចាយមិនដែលចប់ទេ ហើយរូបភាពទាំងនោះមានលក្ខណៈអចិន្ត្រៃយ៍។ [៣]



ក្នុងឆ្នាំ ២០២៤ មានឯកសារចំនួន ៤៥០,០០០ នៃឯកសារស្តីពីអំពើរំលោភបំពានផ្លូវភេទលើកុមារ (CSAM) ដែលបានធ្វើរបាយការណ៍ថា។ នៅឆ្នាំ ២០២២ ចំនួននេះបានហក់កើនឡើងដល់ជាង ៨៧ លាននាក់។ [២]


ប្រភព:

១. យូនីសេហ្វ។ (២០២១)។ ការស៊ើបអង្កេតហានិភ័យ និងឱកាសសម្រាប់កុមារនៅក្នុងពិភពឌីជីថល៖ ការពិនិត្យឡើងវិញយ៉ាងឆាប់រហ័សនៃភស្តុតាងស្តីពីការប្រើប្រាស់អ៊ីនធឺណិតរបស់កុមារ និងលទ្ធផល។ (ទំ.១២) https://www.unicef.org/innocenti/media/5621/file/UNICEF-Investigating-Risks-Opportunities-Children-Digital-World-2021.pd

២.Thorn. (២០២៥).ចេញដោយ. https://www.thorn.org/issue/

៣. មជ្ឈមណ្ឌលជាតិសម្រាប់ការបាត់ខ្លួន និងអំពើកេងប្រវ័ញ្ចលើកុមារ (NCMEC) . (២០២៥)។ ខ្លឹមសារនៃការរំលោភបំពានផ្លូវភេទលើកុមារ។ https://www.missingkids.org/theissues/csam


Global Freedom Summit

21

# សញ្ញាព្រមានដែលអាចនឹងកើតមានលើកុមារ ពេលដែលពួកគេកំពុងត្រូវបានកេងប្រវ័ញ្ចផ្លូវភេទលើអ៊ីនធឺណិត

១

ជួបប្រទះការបែកបាក់ក្នុងទំនាក់ទំនង—ឯកោពីមិត្តភ័ក្តិ ឬក្រុមគ្រួសារ ឬដកខ្លួនចេញពីក្រុមទំនាក់ទំនងក្នុងសង្គមធម្មតា។

២

ការផ្លាស់ប្តូររូបរាង ដូចជាការស្រកទម្ងន់ភ្លាមៗ ឬការផ្លាស់ប្តូរការតុបតែងខ្លួន ឬការជ្រើសរើសសម្លៀកបំពាក់។

៣

ស្រាប់តែមានអំណោយ ឬទ្រព្យសម្បត្តិដែលមិនអាចពន្យល់បកស្រាយពីប្រភពបាន។

៤

មានការពិបាកចិត្ត ដកខ្លួនចេញ ឬថប់បារម្ភ បន្ទាប់ពីប្រើប្រាស់អ៊ីនធឺណិត ឬផ្ញើសារ។

៥

ផ្លាស់ប្តូរនិស្ស័យ—ផ្លាស់ប្តូរអារម្មណ៍ច្រើន ឆាប់មួរម៉ៅ ឬនៅតែម្នាក់ឯង។

៦

ការប្រមូលផ្តុំលេខទូរស័ព្ទ អត្តបទ ឬអាសយដ្ឋានអ៊ីមែលថ្មីៗជាច្រើន។

៧

ពួកគេបង្ហាញអាកប្បកិរិយាលាក់បាំង ជាពិសេសនៅពេលសួរអំពីសកម្មភាពរបស់ពួកគេ។

៨

ការទទួលសារឬការហៅទូរស័ព្ទច្រើនពេក។

៩

លេងទូរសព្ទ ហ្គេម ឬឧបករណ៍អេឡិចត្រូនិចផ្សេងៗទៀតច្រើនហួសប្រមាណ។

១០

ចេញពីផ្ទះដោយមិនប្រាប់ជាមុន ឬឧស្សាហ៍ត្រឡប់មកផ្ទះយឺត។

១១

ពិបាកជាមួយនឹងការគេង ឬទម្លាប់នៃការញ៉ាំ បង្ហាញពីសញ្ញានានាពីការថប់បារម្ភ។

១២

គេចសាលា ឬរំខានក្នុងថ្នាក់។

## ការសិក្សា. ការបំពាក់បំប៉ន. ការការពារ.

ទទួលបានការយល់ដឹងដ៏មានសារៈសំខាន់អំពីអំពើកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអ៊ិនធឺណិត។ ទទួលបានឧបករណ៍សម្ភារៈជាក់ស្តែង និងត្រូវបានផ្តល់នូវសិទ្ធិអំណាចដើម្បីសុវត្ថិភាពកុមារដែលរស់នៅជុំវិញអ្នក—និងមនុស្សជំនាន់ក្រោយក្នុងពេលអនាគតផងដែរ។

**ចូលរួមទស្សនាកិច្ចប្រជុំកំពូលសកលដើម្បីសេរីភាពនៅថ្ងៃនេះ។**

A21.org/FreedomSummit @A21Cambodia